០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

# ឧបសម្ព័ន្ធ

## កាលប្បវត្តិពាក់ព័ន្ធនឹងការសុំចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ

- នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីការពារក្តីលោក អៀង សារី បានផ្ញើអ៊ីមែលមួយជូនទៅ Nisha Valabhji ដែលពេលនោះជាប្រធានស្តីទីនៃអង្គការគាំពារការការពារក្តី ដោយបានលើកឡើងថា៖ “តាមរយៈលិខិតនេះ យើងខ្ញុំស្នើសុំទៅអង្គភាពគាំពារការការពារក្តី ដើម្បីសាកសួរពីបញ្ហាពាក់ព័ន្ធនឹងការសុំចូលប្រើប្រាស់ CaseMap ពីចម្ងាយ ដែលយើងខ្ញុំយល់ថា ត្រូវប្រើប្រាស់តាមរយៈឃ្លាំងផ្ទុកឯកសាររួម (Shared Drive) នោះ។ តាមរយៈកិច្ចសន្ទនារបស់យើងខ្ញុំជាមួយ So Myint [ប្រធានផ្នែកសេវា IT] យើងខ្ញុំបានដឹងថា រាល់បញ្ហាបច្ចេកទេសទាំងអស់ដែលពាក់ព័ន្ធនឹងបញ្ហានេះត្រូវបានដោះស្រាយរួចរាល់ហើយ។ នាពេលនេះ វានៅមានបញ្ហាមួយទៀត គឺការទទួលបានហត្ថលេខាដែលចាំបាច់។ យើងខ្ញុំបានទទួលព័ត៌មានថា យូរនឹងឆាប់យើងខ្ញុំមុខជានឹងទទួលបានការយល់ព្រម ហើយអាចចូលប្រើប្រាស់បានយ៉ាងពេញលេញមិនខាន។ យើងខ្ញុំបានទទួលព័ត៌មាននេះកាលពីពីរបីសប្តាហ៍មុនម្ល៉េះ។ ទន្ទឹមនឹងការដែលយើងខ្ញុំមានទំនុកចិត្តថា មន្ត្រីទាំងអស់ដែលទទួលខុសត្រូវចំពោះបញ្ហានេះកំពុងខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួន ដើម្បីឲ្យភាគីទាំងអស់អាចចូលប្រើប្រាស់ CaseMap / ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ ដោយសារថា សវនាការបានចាប់ផ្តើមទៅហើយនោះ វាជាការសំខាន់ណាស់ដែលថា មន្ត្រីទាំងនោះគួរខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីឲ្យការចូលប្រើប្រាស់ CaseMap/ ឃ្លាំងផ្ទុកឯកសាររួម ពីចម្ងាយត្រូវបានអនុវត្តជាស្ថាពរកាន់តែឆាប់កាន់តែប្រសើរ”។
- នៅចុងខែធ្នូ ឆ្នាំ២០១១ មេធាវីការពារក្តីលោក អៀង សារី បានដឹងថា ការវាយតម្លៃលើបញ្ហាសន្តិសុខមានភាពចាំបាច់ មុនពេលការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមអាចដំណើរការបាន ហើយបញ្ហាបច្ចុប្បន្នគឺការិយាល័យរដ្ឋបាល។

- នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១២ មេធាវីការពារក្តីលោក អៀង សារី បានផ្ញើអ៊ីមែលទៅការិយាល័យរដ្ឋបាល ដោយស្នើសុំព័ត៌មានថ្មីៗពាក់ព័ន្ធនឹងការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួម និង CaseMap ពីចម្ងាយ។ លិខិតនោះបានលើកឡើងថា៖ “យើងខ្ញុំសរសេរលិខិតនេះដើម្បីស្នើសុំព័ត៌មានថ្មីៗថា តើភាគីអាចចូលប្រើប្រាស់ CaseMap ពីចម្ងាយដែលយើងខ្ញុំយល់ថា ត្រូវប្រើប្រាស់តាមរយៈឃ្លាំងផ្ទុកឯកសាររួមនោះឬទេ និងពេលណាទើបភាគីអាចធ្វើបែបនេះបាន។ យើងខ្ញុំបានទទួលព័ត៌មានពីផ្នែក

ICT មកវិញថា រាល់បញ្ហាបច្ចេកទេសទាំងអស់ ដែលពាក់ព័ន្ធនឹងបញ្ហានេះត្រូវបានដោះស្រាយរួចរាល់ហើយ ហើយថា នាពេលនេះ វានៅមានបញ្ហាមួយទៀតគឺការទទួលបានហត្ថលេខាពីការិយាល័យរដ្ឋបាលតែប៉ុណ្ណោះ។ ទន្ទឹមនឹងការដែលយើងខ្ញុំមានទំនុកចិត្តថា មន្ត្រីទាំងអស់ដែលទទួលខុសត្រូវចំពោះបញ្ហានេះកំពុងខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួន ដើម្បីឱ្យភាគីទាំងអស់អាចចូលប្រើប្រាស់ CaseMap/ ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ ដោយសារថា សវនាការបានចាប់ផ្តើមទៅហើយនោះ វាជាការសំខាន់ណាស់ដែលថា មន្ត្រីទាំងនោះគួរខឹតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីឱ្យការចូលប្រើប្រាស់ CaseMap/ ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយត្រូវបានអនុវត្តជាស្ថាពរកាន់តែឆាប់កាន់តែប្រសើរ។ បើមិនអាចចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយទេនោះ លទ្ធភាពនៃការបំពេញការងារក្រៅពីពេលនៅក្នុងបន្ទប់សវនាការដូចជានៅពេលយប់ និងថ្ងៃចុងសប្តាហ៍នោះ នឹងមានកាន់តែតិចតួចមិនខាន”។ មេធាវីការពារក្តីមិនទាន់បានទទួលការឆ្លើយតបណាមួយពីការិយាល័យរដ្ឋបាលទេ។

- នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ មេធាវីការពារក្តីលោក អៀង សារី បានផ្ញើអ៊ីមែលមួយទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយមានសំណួរមួយចំនួនពាក់ព័ន្ធនឹងការរៀបចំសវនាការ រួមមានដូចជា៖ “តើអង្គជំនុំជម្រះសាលាដំបូងមានតួនាទីជួយភាគីក្នុងការទទួលបានការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួម និង CaseMap ពីចម្ងាយឬទេ? យើងខ្ញុំបានទទួលព័ត៌មានជាងមួយខែមកហើយថា រាល់បញ្ហាបច្ចេកទេសទាំងអស់ ដែលពាក់ព័ន្ធនឹងបញ្ហានេះត្រូវបានដោះស្រាយរួចរាល់ហើយ ហើយថា នាពេលនេះ វានៅមានបញ្ហាមួយទៀតគឺរង់ចាំការការអនុម័តយល់ព្រមពីការិយាល័យរដ្ឋបាលតែប៉ុណ្ណោះ។ ការពន្យារមិនឱ្យយើងខ្ញុំអាចចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ បានប៉ះពាល់ជាអវិជ្ជមានដល់លទ្ធភាពរបស់យើង ក្នុងការរៀបចំឯកសារសម្រាប់សវនាការបាន ដោយសារយើងខ្ញុំមិនអាចចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួម និង CaseMap ពីចម្ងាយ នៅពេលយប់ និងថ្ងៃចុងសប្តាហ៍។ សូមលោកស្រីអានលិខិតភ្ជាប់មកជាមួយដែលក្រុមយើងខ្ញុំបានផ្ញើទៅការិយាល័យរដ្ឋបាលកាលពីម្សិលមិញ”។

- នៅឯកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការ កាលពីថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីថា លោកស្រីចៅក្រម Cartwright នឹងលើកឡើងនូវបញ្ហាការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ ជាមួយលោក Knut Rosandhaug អនុ

ប្រធានការិយាល័យរដ្ឋបាល។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley បានគូសបញ្ជាក់ថា ក.ស.ព គាំទ្រសំណើរបស់មេធាវីការពារក្តីលោក អៀង សារី និងថា ការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយគឺជាបញ្ហាមួយសម្រាប់ភាគីទាំងអស់ ជាពិសេសដោយសារថា ការិយាល័យ អ.វ.ត.ក នៅក្រុងភ្នំពេញនឹងត្រូវបិទទ្វារក្នុងពេលឆាប់នេះ (ការិយាល័យនេះបានបិទទ្វាររួចហើយ)។ គាត់បានលើកឡើងថា គាត់បានឮថា ការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយអាចធ្វើបានតាមលក្ខណៈបច្ចេកទេស ហើយរាល់បញ្ហាបច្ចេកទេសទាំងអស់ដែលពាក់ព័ន្ធនឹងបញ្ហានេះត្រូវបានដោះស្រាយរួចរាល់ហើយ តែបញ្ហាគឺថា មានការវាយតម្លៃអវិជ្ជមានពីផ្នែកសន្តិសុខ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានលើកឡើងថា គាត់ជឿថា វាមានហានិភ័យផ្នែកសន្តិសុខកាន់តែធំជាងនេះ នៅពេលដែលមន្ត្រីទាំងអស់ប្រើប្រាស់បន្ទះផ្ទុកទិន្នន័យខ្នាតតូច (flash drives) នៅពេលពួកគេធ្វើការពីចម្ងាយ ដោយសារពួកគេមិនអាចប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមបាន។ គាត់បានលើកឡើងថា គាត់មានផែនការស្នើសុំឲ្យមានការវាយតម្លៃពីបញ្ហាសន្តិសុខជាលើកទីពីរ និងបានស្នើឲ្យភាគីដទៃទៀតគាំទ្រដល់សំណើរបស់គាត់ផង។

- ក្នុងពេលប្រជុំរៀបចំសវនាការ នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីថា លោកស្រីចៅក្រម Cartwright មិនទាន់បាននិយាយជាមួយលោក Rosandhaug អំពីការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយទេ។

- នៅថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារក្តីលោក អៀង សារី បានផ្ញើអ៊ីមែលមួយទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយស្នើសុំព័ត៌មានថ្មីៗពាក់ព័ន្ធនឹងការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ នៅឯកិច្ចប្រជុំរៀបចំសវនាការនាថ្ងៃបន្ទាប់។

- ក្នុងពេលប្រជុំរៀបចំសវនាការ នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា លោកស្រីចៅក្រម Cartwright កំពុងជួបប្រជុំជាមួយលោក Knut Rosandhaug នៅថ្ងៃនោះ វេលាម៉ោង ១:០០ រសៀល ហើយប្រធានបទមួយក្នុងចំណោមប្រធានបទនានាដែលគាត់យកមកពិភាក្សាគឺ ការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ ហេតុនេះគួរតែមានព័ត៌មានថ្មីៗ នៅឯកិច្ចប្រជុំរៀបចំសវនាការនាសប្តាហ៍បន្ទាប់។

- នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងតាមរយៈអ៊ីមែលផ្ញើជូនភាគី (ជាការឆ្លើយតបទៅនឹងសំណួរមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានចម្លងជូនភាគីទាំងអស់) ថា៖ "លោកស្រីចៅក្រម Cartwright កំពុងបន្តទាក់ទងជាមួយអនុប្រធានការិយាល័យរដ្ឋបាល ពាក់ព័ន្ធនឹងបញ្ហានេះ ហើយនឹងបន្តលើកឡើងនូវបញ្ហានេះដែរ។ ខ្ញុំសូមជូនដំណឹងដល់អស់លោកវិញ នៅពេលខ្ញុំបានទទួលព័ត៌មានបន្ថែមទៀត"។

- នៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១២ មេធាវីការពារក្តីលោក អៀង សារី បានផ្ញើអ៊ីមែលមួយទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីសាកសួរថា តើមានព័ត៌មានថ្មីៗពាក់ព័ន្ធនឹងការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយឬទេ។ នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់បានជូនដំណឹងវិញថា គាត់មិនទាន់បានទទួលព័ត៌មានថ្មីៗក្នុងដំណាក់កាលនេះទេ។

- នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ មេធាវីការពារក្តីលោក អៀង សារី បានផ្ញើអ៊ីមែលមួយទៅកាន់ការិយាល័យរដ្ឋបាល ដោយស្នើសុំឲ្យមានកិច្ចប្រជុំមួយដើម្បីពិភាក្សាពីស្ថានភាពនៃការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយ។ លិខិតនោះបានលើកឡើងថា៖ "តើលោកអាចរៀបចំឲ្យមានកិច្ចប្រជុំខ្លីមួយ ដើម្បីពិភាក្សាពីស្ថានភាពនៃលទ្ធភាពក្នុងការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួម (S Drive) ដោយរួមទាំងបណ្តុំឯកសារប្រតិចារឹកស្តីពីសវនាការបានឬទេ? យើងខ្ញុំបានស្នើសុំការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយរួចមកហើយ ហើយយើងខ្ញុំក៏បានទទួលដំណឹងថា ការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយកំពុងត្រូវបានពិចារណា តែយើងខ្ញុំមិនទាន់បានព័ត៌មានថ្មីៗពាក់ព័ន្ធនឹងបញ្ហានេះទេ។ ការដែលយើងមិនអាចចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួមពីចម្ងាយបានជះឥទ្ធិពលជាអវិជ្ជមានដល់ផលិតភាពរបស់យើង។ យើងត្រូវនៅ (ឬធ្វើដំណើរតាមរថយន្ត) ទៅ អ.វ.ត.ក ក្រៅម៉ោងរដ្ឋបាលធម្មតា (ដែលមិនអាចធ្វើបានជានិច្ចកាល) ឬយើងត្រូវខកខានមិនបានប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួម ហើយត្រូវរក្សាឯកសាររបស់យើងនៅក្នុងបន្ទះផ្ទុកទិន្នន័យខាងក្រៅ (external hard drives) ដែលយើងត្រូវយកតាមខ្លួនទៅមកការិយាល័យជារៀងរាល់ថ្ងៃ។ ជម្រើសទាំងពីរនេះពុំមែនជាការល្អទេ ហើយជម្រើសនីមួយៗសុទ្ធតែមានបញ្ហារបស់វាផ្ទាល់។ ការប្រជុំដើម្បីពិភាក្សាពីបញ្ហានេះទេទើបជាការប្រសើរបំផុត ដោយសារថា បញ្ហានេះត្រូវកំពុងស្ថិតក្នុងការពិចារណាមុនពេលចាប់ផ្តើមសវនាការ។ យើងខ្ញុំយល់ឃើញថា "វាជាការប្រសើរដែលអញ្ជើញក្រុមមេធាវីការពារក្តីដទៃទៀត ក.ស.ព និង ដើម

បណ្តឹងរដ្ឋប្បវេណីមកចូលរួមក្នុងកិច្ចប្រជុំនេះដែរ ដោយសារបញ្ហានេះក៏ប៉ះពាល់ដល់ពួកគេដូចគ្នានេះដែរ"។ ទោះបីការពិតថា មានការបញ្ជាក់ពីការទទួលបានអ៊ីមែលក៏ដោយ ក៏មកទល់ពេលនេះការិយាល័យរដ្ឋបាលមិនទាន់បានឆ្លើយតបនឹងសារនេះទេ"។

- នៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ក្នុងនាមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី Jeanne Sulzer បានឆ្លើយតបតាមរយៈអ៊ីមែល ដោយផ្ញើជូនទៅការិយាល័យរដ្ឋបាលថា៖ "ដូចដែលបានលើកឡើងជាច្រើនដងមកហើយក្នុងកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការនានាថា បញ្ហានេះក៏មានសារៈសំខាន់ជាពិសេសដែរសម្រាប់សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសដោយសារ មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមានអាសយដ្ឋាននៅក្រៅប្រទេសកម្ពុជា។ ហេតុនេះ យើងខ្ញុំគាំទ្រសំណើរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ដែលសុំឲ្យមានកិច្ចប្រជុំមួយ និងសំណើនានាក្នុងគោលបំណងធានាឲ្យមានការចូលប្រើប្រាស់ឃ្លាំងផ្ទុកឯកសាររួម (រួមទាំង text map និង case map) និងសំណុំឯកសារប្រតិចារឹកផងដែរ"។